អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងស្បៀងអាហារសម្រាប់ការអប់រំ

# ប័ណ្ណណែនាំអំពីរបៀបដឹកនាំ ការសិក្សាលម្អិតលើមេរៀន

## ការស្រាវជ្រាវ

មានការស្រាវជ្រាវជាច្រើន អំពីវិធីដែលយើងអាចកែលម្អការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ លីធល និង ខូចរ៉ាន ស្មីត (១៩៩៤) បានសរសេរថា កម្មវិធីអប់រំគ្រូបង្រៀន គួរបង្រៀនគ្រូថា រៀនដើម្បីបង្រៀន គឺជាដំណើរការដែលចាំបាច់ ត្រូវបំពេញមុនការចាប់យកអាជីព ជាគ្រូបង្រៀន។ ការអនុវត្តវិជ្ជាជីវៈ គឺជាដំណើរបង្កើតនិងកំណត់បញ្ហា របស់បញ្ហាដោយគ្រូខ្លួនឯងផ្ទាល់។ ក្នុងដំណើរឆ្ពោះទៅចាប់យកអាជីពជាគ្រូបង្រៀន ទាមទារឲ្យមានការបង្កើត ទំនាក់ទំនងថ្មី ហើយប្លែកក្នុងចំណោមគ្រូបង្រៀន និងចំណេះដឹងដែលពួកគេបង្កើត។ ជាឧទាហរណ៍: គ្រូនឹងរៀនអំពីអ្វីៗជាច្រើនពីកុមារ និងសកម្មភាពនៅក្នុងថ្នាក់។ ប្រសិនបើយើងអភិវឌ្ឍសមត្ថភាពគ្រូ ដោយវិភាគយ៉ាងល្អិតល្អន់ លើបទពិសោធរបស់ពួកគេផ្ទាល់ យើងនឹងអាចជួយពួកគេ ឲ្យបង្កើតបាននូវវិធីសាស្ត្រ សម្រាប់ដោះស្រាយបញ្ហាដែលអាចកើតមានឡើង ក្នុងអាជីពរបស់ពួកគេក្នុងរយៈពេលវែង។

*ការសិក្សាលម្អិតលើមេរៀន គឺជាឧបករណ៍សម្រាប់អភិវឌ្ឍវិជ្ជាជីវៈ ដែលគ្រូសិក្សាអំពីមេរៀនមួយឬច្រើន ដើម្បីអភិវឌ្ឍ និងពង្រឹងចំណេះដឹងឲ្យកាន់តែស៊ីជម្រៅអំពីខ្លឹមសារ បំណិន ឬប្រធានបទ។ សាលាបឋមសិក្សារបស់ប្រទេសជប៉ុនប្រើប្រាស់កម្មវិធីសិក្សាលម្អិត ពីមេរៀនជាមធ្យោបាយសម្រាប់គ្រូចែករំលែក និងពិភាក្សាគ្នាអំពីការអនុវត្តរបស់ពួកគេនៅក្នុងថ្នាក់។ គោលវិធីសិក្សា លម្អិតពីមេរៀនត្រូវបានប្រើផងដែរសម្រាប់បង្កើនចំណេះដឹងគរុកោសល្យ និងជំនាញរបស់ គ្រូតាម*

*រយៈវិធីសាស្ត្រសហការ, ការផ្ដល់មតិស្ថាបនា, ការឆ្លុះបញ្ចាំងគ្នា, និង ការវិភាគលើបញ្ហាផ្សេងៗ។*






*ការសិក្សាលម្អិតលើមេរៀនគឺទាក់ទងការសិក្សាលើមេរៀនដែលត្រូវបាន ធ្វើផែនការ ស្រាវជ្រាវ អនុវត្ត វាយតម្លៃ និង កែលម្អរួចហើយ។ គោលវិធីនៃការសិក្សាលម្អិតលើមេរៀន គឺដើម្បីបង្កើនចំណេះដឹងគរុកោសល្យ និងបំណិនឲ្យកាន់តែស៊ីជម្រៅតាមរយៈ ការសហការ ការផ្ដល់មតិកែលម្អ និងវិធីសាស្ត្រវិភាគ។ គោលវិធីអនុញ្ញាតិឲ្យសាលាបណ្ដុះនូវ សហគមសិក្សាសកម្មក្នុងចំណោមគ្រូបង្រៀន។*

## សេចក្ដីណែនាំសម្រាប់ ការសិក្សាលម្អិតលើមេរៀន

1. នៅក្នុងក្រុមរបស់អ្នក ជ្រើសរើសវិធីសាស្ត្របង្រៀន មួយសម្រាប់ធ្វើផែនការសកម្មភាព បង្រៀន ដូចជា ការគាំទ្រដល់សិស្សរៀនយឺត ការបង្កើនការចូលរួមរបស់សិស្ស ។ល។

2. ជ្រើសរើសសកម្មភាពរៀនភាសាមួយ ដែលអាចបង្ហាញបានល្អអំពីវិធីសាស្រ្តបង្រៀន ដែលអ្នកចង់កែលម្អ (ត្រង់នេះអាចជា មេរៀនដែលអ្នកបានបង្រៀនរួចហើយ គ្រាន់តែយកវាមកបង្ហាញវិញដល់គ្រូដទៃតែប៉ុណ្ណោះ)។
3. ធ្វើការសម្រេចអំពីពេលវេលាដែលអ្នកត្រូវអនុវត្តសកម្មភាពនេះ ដើម្បីឲ្យគ្រូដទៃមើល និង ពិភាក្សាក្រោយពេលអ្នកបង្រៀនរួច។
4. គ្រូដទៃនឹងសង្កេតហើយកត់ត្រានៅពេលដែលអ្នកបង្រៀន នៅក្នុងថ្នាក់។
5. ក្រោយពីអ្នកបង្រៀនចប់ អ្នកនិងគ្រូដទៃទៀត គួរពិភាក្សាអំពីការបង្រៀនរបស់អ្នក ថាតើវាប្រព្រឹត្តទៅយ៉ាងដូចម្តេច។ ផ្តោតការពិភាក្សាលើតែវិធីសាស្រ្តបង្រៀន ដែលអ្នកបានឯកភាពគ្នាជ្រើសរើសយករួចហើយ។ ពិភាក្សារកចំណុចល្អ និង ចំណុចដែលត្រូវកែលម្អ។
6. គ្រូនីមួយៗយកមេរៀន និងវិធីសាស្រ្តដែលបានពិភាក្សារួចហើយទៅអនុវត្តរៀងៗខ្លួន។

**វីដេអូនៅក្នុងយូធូប៖**

https://cambodia.worlded.org/our-projects/resources/

វីដេអូទាំងបីភាគបង្ហាញអំពី វិធីសម្របសម្រួលសកម្មភាព នៃការសិក្សាលម្អិតលើមេរៀន ជាមួយនិងគ្រូដទៃនៅសាលារបស់អ្នក។ ភាគទី១ បង្ហាញអំពីគ្រូចូលរួមសហការ និងពិភាក្សាអំពីមេរៀន។ ភាគ២ បង្ហាញអំពីការអនុវត្តបង្រៀនមេរៀន ហើយភាគទី៣ បង្ហាញអំពី ការពិភាក្សា ឆ្លុះបញ្ចាំងក្រោយការបង្រៀនបង្ហាញចប់។

សម្រាប់វីដេអូ និងធនធានដទៃទៀតសូមចូលមើលតាមវេបសៃខាងក្រោមនេះ៖

bit.ly/KhmerLiteracy